**វគ្គបណ្តុះបណ្តាលស្តីពី"ពង្រឹងសមត្ថភាពក្នុងការប្រមូល ការវិភាគ និងការប្រើប្រាស់ទិន្នន័យ ដល់បុគ្គលិកនៅគ្លីនិកសុខភាពគ្រួសារ និងមន្ត្រីទិន្នន័យថ្នាក់ខេត្ត "**

===========================

**ខេត្តកំពង់ចាម ៖** ថ្ងៃអង្គារ ពុធ ១១ ដល់ ១២រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី ១២ ដល់ ១៣ ខែឧសភា ឆ្នាំ២០២៦ ផ្នែកគ្រប់គ្រងទិន្នន័យ និងផ្នែកគ្រប់គ្រងព្យាបាលជំងឺបង្កតាមការរួមភេទនិងប្រដាប់បន្តពូជមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ សហការជាមួយមួយមន្ត្រីបច្ចេកទេស នៃគម្រោងEpiC FHI 360 បានរៀបចំ **វគ្គបណ្តុះបណ្តាលស្តីពី"ពង្រឹងសមត្ថភាពក្នុងការប្រមូល ការវិភាគ និងការប្រើប្រាស់ទិន្នន័យ ដល់បុគ្គលិកនៅ គ្លីនិកសុខភាពគ្រួសារ និងមន្ត្រីទិន្នន័យថ្នាក់ខេត្ត** ។វគ្គបណ្តុះបណ្តាលនេះ មានសិក្ខាកាមចូលរួម ៧០ នាក់ ដែលជាមន្ត្រីគ្រប់គ្រង ទិន្នន័យ ខេត្ត មន្ត្រីផ្នែកគ្លីនិកសុខភាពគ្រួសារ ២៥ ខេត្តរាជធានី ។ វគ្គបណ្តុះបណ្តាលនេះ ឧបត្ថម្ភថវិកាដោយគម្រោង

EpiC FHI 360 ។

ពិធីបើកវគ្គបណ្តុះបណ្តាលនេះ ដោយ**លោកវេជ្ជបណ្ឌិត ម៉ែន ប៊ុណ្ណា** អនុប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ចាម និង**លោកវេជ្ជ កាអឿន ចិត្រា** តំណាង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ ។






**<u>វត្ថុបំណងសម្រាប់វគ្គបណ្តុះបណ្តាល</u>** (Specific Objectives of Training):

- ដើម្បីធ្វើឱ្យប្រសើរឡើងនូវការធ្វើរោគវិនិច្ឆ័យ និងការគ្រប់គ្រងព្យាបាលជំងឺកាមរោគ
- ដើម្បីណែនាំ និង បង្ហាញពី ទម្រង់ដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់គ្លីនិកសុខភាពគ្រួសារ
- ដើម្បីយល់ដឹងពីប្រពន្ធ័ និងអាច បញ្ចូលទិន្នន័យជំងឺកាមរោគសម្រាប់គ្លីនិកសុខភាពគ្រួសារ។
- សមត្ថភាពក្នុងការប្រើប្រាស់របាយការណ៍ ប្រចាំខែ ត្រីមាស ឆ្នាំ និង *Dashboard*

**<u>២.លទ្ធផលរំពឹងទុក</u>** (Expected outcome)

- ធ្វើការកែលម្អឡើងវិញពីរការផ្តល់សេវានៅគ្លីនិកឯកទេសជំងឺកាមរោគ
- កត់ត្រានិងបញ្ចូលទិន្នន័យជំងឺកាមរោគ(STI Database) នៅគ្លីនិកសុខភាពគ្រួសារត្រូវបាកែលម្អ។
- ចេះបញ្ចូលទិន្នន័យជំងឺកាមរោគ(STI Database) នៅតាមគ្លីនិកសុខភាពគ្រួសារនិមួយចេះទាញរបាយការណ៍ និងតាមដានករណី ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ











